សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហា
កេងប្រវ័ញ្ច (ផ្លូវភេទ) លើកុមារក្នុងប្រទេសកម្ពុជា
NGO Coalition to Address (Sexual) Exploitation of Children in Cambodia [COSECAM]

# ដំណឹងជ្រើសរើសបុគ្គលិកស្ម័គ្រចិត្ត

**PSA** គឺជាសមាគមផ្តល់សេវាចិត្តសង្គម **(Psycho-social Services Association)** ដែលបានបង្កើតឡើងនៅឆ្នាំ ២០០៨ ក្រោមការឧបត្ថម្ភគាំទ្រដោយមូលនិធិ ANESVAD តាមរយៈសម្ព័ន្ធអង្គការកូសេកាំ។ គោលបំណងរបស់សមាគមគឺដើម្បីផ្តល់នូវសេវាពិគ្រោះយោបល់ខាងចិត្តសង្គមទៅដល់កុមារ និងស្ត្រីដែលរងគ្រោះ និងងាយរងគ្រោះដោយការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទ និងការកសាងសមត្ថភាពដល់បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកផងដែរ។ បច្ចុប្បន្ននេះសមាគមមានសមាជិកចំនួន ១០ នាក់ និងមានការិយាល័យតាំងនៅរាជធានីភ្នំពេញ។ ដើម្បីសំរួលដល់ការងាររបស់ខ្លួន សមាគមត្រូវការជ្រើសរើសបុគ្គលិកស្ម័គ្រចិត្តចំនួន១នាក់ ដើម្បីបំពេញតួនាទីជា **"ជំនួយការរដ្ឋបាល និងគណនេយ្យ"** ។ *សូមបញ្ជាក់ថា សមាគមនឹងផ្តល់ប្រាក់ឧបត្ថម្ភដល់បុគ្គលិកស្ម័គ្រចិត្តចំនួន ៥០ ដុល្លា (ហាសិបដុល្លា) និងប្រាក់សម្រាប់មធ្យោបាយធ្វើដំណើរ ចំនួន ១០ ដុល្លា (ដប់ដុល្លា) ក្នុងមួយខែ។*

## ១. លក្ខណៈសម្បត្តិ

- ទាំងពីរភេទ មានអាយុចាប់ពី ២២ ដល់ ៣៥ ឆ្នាំ។
- ជានិសិ្សតឆ្នាំ ទី៣ ឡើងទៅ ដែលរៀនជំនាញផ្នែករដ្ឋបាល និង គណនេយ្យ ។
- មានពេលវេលាយ៉ាងតិច៣ម៉ោងក្នុង១ថ្ងៃដើម្បីបំពេញការងារ។
- មានឆន្ទៈ និងសកម្មក្នុងការបំពេញការងារ។
- មានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន។
- រួសរាយរាក់ទាក់ និង មានទំនាក់ទំនងល្អ។

## ២. ភារកិច្ច និងការទទួលខុសត្រូវ

### ក.ការងាររដ្ឋបាល

- រៀបចំ គ្រប់គ្រង ការិយាល័យ ។
- រៀបចំ និង គ្រប់គ្រងឯកសារ ។
- នៅប្រចាំការក្នុងការិយាល័យពេលម៉ោងធ្វើការ។

- ជួយទំនាក់ទំនងជាមួយអង្គការ/ស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលឯកសារ និងពត៌មានផ្សេងៗតាមតម្រូវការជាក់ស្តែង។
- រៀបចំប្រជុំប្រចាំខែ ដូចជា រៀបចំលិខិតអញ្ជើញ ទូរស័ព្ទជូនដំណឹង រៀបចំទីកន្លែង និងសម្ភារៈប្រជុំ។

**ខ.ការងារគណនេយ្យ**

- ចូលរួមរៀបចំផែនការចំណាយ និងតាមដានការចំណាយប្រចាំខែ ។
- ជួយរៀបចំវិក័យប័ត្រ និងបញ្ជីចំណាយដើម្បីទូទាត់ជាមួយគណនេយ្យកូសេកាំ ។
- ចូលរួមធ្វើផែនការថវិកាប្រចាំឆ្នាំ ។
- រៀបចំ និង ថែរក្សាឯកសារទាក់ទងនឹងថវិកា ។

បេក្ខជនដែលមានចំណាប់អារម្មណ៏សូមសរសេរពាក្យសុំ និងប្រវត្តិរូបសង្ខេបដែលមានបិទរូបថត ៤x៦ ផ្ញើមកកាន់ការិយាល័យសម្ព័ន្ធអង្គការកូសេកាំ ដែលមានអាសយដ្ឋាន បន្ទប់លេខ៥៩៤ ជាន់ទី៥ អគារ F មជ្ឈមណ្ឌលភ្នំពេញ ភ្នំពេញ។

បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៏។ ការទទួលពាក្យនឹងចាប់ផ្តើមពីថ្ងៃទី ២៤ សីហា ២០០៩ រហូតដល់ថ្ងៃទី ០៤ ខែ កញ្ញា ២០០៩ ត្រឹមម៉ោង ១៧:០០។ ចំពោះពត៌មានលំអិតសូមទំនាក់ទំនងលោកស្រី **កៅ សុខជែត** តាមរយៈទូរស័ព្ទលេខ ០១២ ៥៣៣ ១៣៥ ។